00876916

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception):
08 / 01 / 2013
ម៉ោង (Time/Heure) : 15:16
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: UCH ARUN

E236/4

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**អង្គជំនុំជម្រះសាលាដំបូង** **សាធារណៈ / Public**

ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៣

**ជូនចំពោះ:** **ភាគីទាំងអស់នៃសំណុំរឿង ០០២**

**ពី:** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន:** **លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង, អង្គភាពគាំពារសាក្សី និងអ្នកជំនាញ**

**កម្មវត្ថុ:** **ការកំណត់កាលបរិច្ឆេទស្តាប់សក្ខីកម្មសាក្សី និងអ្នកជំនាញ សម្រាប់ដើមឆ្នាំ ២០១៣**

១. នៅថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានកំណត់កាលបរិច្ឆេទស្តាប់សក្ខីកម្មរបស់លោក Phlilip SHORT (TCE-65) និងលោកស្រី Elizabeth BECKER នៅខែ តុលា ឆ្នាំ ២០១២ (E172/24)។ ដោយសារតែជនជាប់ចោទ អៀង សារី ត្រូវចូលសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ នៅថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១២ នោះ អង្គជំនុំជម្រះបានពន្យាពេលស្តាប់សក្ខីកម្មអ្នកជំនាញទាំងពីររូប រហូតដល់ពេលមានការជូនដំណឹងជាថ្មី (E233)។ នៅថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីនានាថា សវនាការស្តាប់សក្ខីកម្មសាក្សីពាក់ព័ន្ធនឹងរចនាសម្ព័ន្ធយោធា រួមទាំងការស្តាប់សក្ខីកម្មរបស់លោក Philip SHORT និង លោកស្រី Elizabeth BECKER នឹងត្រូវចាប់ផ្តើមឡើងវិញនៅក្នុងខែ ធ្នូ ឆ្នាំ ២០១២ និងពេលសវនាការបន្តបន្ទាប់ក្រោយមកទៀត។ អង្គជំនុំជម្រះក៏បានជូនដំណឹងដល់ភាគីនានាផងដែរថា លោក Stephen HEDER (TCE-33) ក៏នឹងត្រូវកោះហៅមក

ផ្តល់សក្ខីកម្មដែរ (E236/2)។ ក្នុងពេលនេះ អង្គជំនុំជម្រះកំណត់កាលបរិច្ឆេទសម្រាប់សក្ខីកម្ម របស់អ្នកជំនាញ តាមកាលបរិច្ឆេទដូចតទៅនេះ៖

ក. លោកស្រី Elizabeth BECKER (TCE-80) ថ្ងៃទី ១១, ១២, ១៣, ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៣ (០៤ ថ្ងៃ)

ខ. លោក Philip SHORT (TCE-65) ថ្ងៃទី ០៤, ០៥, ០៦, ០៧ ខែ មីនា ឆ្នាំ ២០១៣ (០៤ថ្ងៃ)

គ. លោក Stephen HEDER (TCE-33) ថ្ងៃទី ២៥, ២៦, ២៧, ២៨ ខែ មីនា ឆ្នាំ ២០១៣ (០៤ ថ្ងៃ)

២. អង្គជំនុំជម្រះសាលាដំបូងនឹងចាប់ផ្តើមសួរសំណួរទៅអ្នកជំនាញ TCE-80 និង TCE-65 រយៈពេលមួយថ្ងៃ សម្រាប់អ្នកជំនាញម្នាក់ៗ។ សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខនឹង មានពេលវេលាមួយថ្ងៃកន្លះ សម្រាប់សួរសំណួរទៅអ្នកជំនាញ TCE-80 និង TCE-65 ហើយ ក្រុមមេធាវីការពារក្តីនឹងមានពេលវេលាមួយថ្ងៃកន្លះ សម្រាប់ការតាំងសំណួរដែរ។ អង្គជំនុំ ជម្រះសាលាដំបូងប្រគល់ភារកិច្ចទទួលខុសត្រូវក្នុងការតាំងសំណួរទៅអ្នកជំនាញ TCE-33 ទៅឱ្យសហព្រះរាជអាជ្ញា។ សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខនឹងមានពេលវេលាមួយ ថ្ងៃកន្លះរួមគ្នា សម្រាប់សួរសំណួរទៅអ្នកជំនាញ TCE-33 ហើយក្រុមមេធាវីការពារក្តីទាំងបី ក្រុមនឹងមានពេលវេលាមួយថ្ងៃកន្លះ សម្រាប់សួរសំណួរដែរ។ អង្គជំនុំជម្រះអាចនឹងត្រូវការ រយៈពេលមួយថ្ងៃដើម្បីសួរសំណួរទៅសាក្សីជំនាញ TCE-33។ អង្គជំនុំជម្រះកត់សម្គាល់ផង ដែរថា អង្គជំនុំជម្រះបានកាត់បន្ថយរយៈពេលផ្តល់សក្ខីកម្មពីលើរយៈពេលដែលបានប្រកាស កាលពីពេលមុនដែលមានក្នុងឯកសារ E172/24 ហើយអង្គជំនុំជម្រះជម្រុញដល់ភាគីនានាឱ្យ ធ្វើការកម្រិតការសួរសំណួរតែទៅលើប្រធានបទណាដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ ប៉ុណ្ណោះ។ អង្គជំនុំជម្រះធ្វើការបញ្ជាក់ថា អង្គជំនុំជម្រះបានទទួលឯកសារ E236/2/2 ហើយ អង្គជំនុំជម្រះនឹងចេញសេចក្តីសម្រេចទៅលើបញ្ហានេះនៅក្នុងពេលវេលាសមស្របខាងមុខ។

៣. អង្គជំនុំជម្រះសូមធ្វើការកត់សម្គាល់បន្ថែមទៀតផងដែរថា អង្គជំនុំជម្រះបានអនុញ្ញាតទៅតាម សំណើរបស់ក្រុមមេធាវីការពារក្តី នួន ជា និង ខៀវ សំផន ដែលស្នើសុំកោះហៅសាក្សី TCW-126 និង TCW-570 (E236, E236/2)។ អង្គជំនុំជម្រះប្រគល់ភារកិច្ចទទួលខុសត្រូវ ក្នុងការសួរសំណួរសាក្សីទាំងនេះទៅក្រុមមេធាវីការពារក្តី នួន ជា (សម្រាប់សាក្សី TCW-126) និងក្រុមមេធាវីការពារក្តី ខៀវ សំផន (សម្រាប់សាក្សី TCW-570)។

៤. អង្គជំនុំជម្រះនឹងចាប់ផ្តើមសួរសំណួរទៅសាក្សី TCW-536 ហើយការសួរសំណួរនេះទំនង ចំណាយពេលត្រឹមមួយថ្ងៃ។ សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខ នឹងត្រូវបានទទួលការ បែងចែកពេលវេលារយៈពេលកន្លះថ្ងៃដើម្បីសួរសំណួរទៅកាន់សាក្សី ហើយក្រុមមេធាវី ការពារក្តីទាំងអស់នឹងត្រូវបានទទួលរយៈពេលមួយថ្ងៃដើម្បីសួរសំណួរសាក្សី។ អង្គជំនុំជម្រះ សូមបញ្ជាក់ថា អង្គជំនុំជម្រះបានអនុញ្ញាតតាមសំណើរបស់សហព្រះរាជអាជ្ញាក្នុងការកោះ ហៅសាក្សី TCW-161 និង TCW-565 ជំនួសឱ្យសាក្សី TCW-285 (ដែលបានទទួល មរណភាព) និង ដើមបណ្តឹងរដ្ឋប្បវេណី TCCP-45 (ឯកសារលេខ E236/1/2)។ សាក្សី TCW-161 មិនអាចមកផ្តល់សក្ខីកម្មបាន ដូច្នេះសាក្សីរូបនេះនឹងមិនត្រូវបានកោះហៅនោះទេ (E236/2/1)។

៥. ជាចុងក្រោយ អង្គជំនុំជម្រះកត់សម្គាល់ថា ខ្លួនបានធ្វើការកំណត់កាលបរិច្ឆេទឡើងវិញ សម្រាប់អ្នកជំនាញវេជ្ជសាស្ត្រ ក្នុងការពិនិត្យមើលសុខភាព និងសម្បទារបស់ជនជាប់ចោទ នៅសប្តាហ៍នៃថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៣ (សូមមើលការកំណត់កាលបរិច្ឆេទមុន នៅក្នុង ឯកសារ E256)។ អង្គជំនុំជម្រះបានផ្តល់ពេលវេលាដល់ភាគីឱ្យបានច្រើនបំផុតតាមដែលអាច ធ្វើទៅបានដើម្បីពិនិត្យមើលលើរបាយការណ៍មុនពេលស្តាប់សក្ខីកម្មរបស់អ្នកជំនាញ ហើយ ដែលការផ្តល់ពេលវេលានេះ គឺអាស្រ័យទៅនឹងលទ្ធភាពរបស់អ្នកជំនាញក្នុងការមកផ្តល់ សក្ខីកម្ម ព្រមទាំងកាលបរិច្ឆេទសវនាការផ្សេងទៀតផងដែរ។ អ្នកជំនាញវេជ្ជសាស្ត្រនឹងវាយ តម្លៃជនជាប់ចោទចាប់ពីថ្ងៃទី ១៧ ដល់ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៣។ ភាគីនានានឹងទទួល បានការជូនដំណឹងពីរបាយការណ៍របស់អ្នកជំនាញទាក់ទងនឹង អៀង សារី យ៉ាងយូរបំផុត ត្រឹមបញ្ចប់ម៉ោងធ្វើការងារក្នុងថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៣ ហើយសវនាការនឹងត្រូវធ្វើឡើង ពាក់ព័ន្ធនឹងបញ្ហាសុខភាព និងសម្បទារបស់ អៀង សារី នៅថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៣។ ភាគីនានានឹងទទួលបានការជូនដំណឹងពីរបាយការណ៍របស់អ្នកជំនាញទាក់ទងនឹង នួន ជា យ៉ាងយូរបំផុតត្រឹមបញ្ចប់ម៉ោងធ្វើការងារក្នុងថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ ហើយសវនាការ នឹងត្រូវធ្វើឡើងពាក់ព័ន្ធនឹងបញ្ហាសុខភាព និងសម្បទារបស់ នួន ជា នៅថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០១៣។

៦. ជារួម កាលបរិច្ឆេទសម្រាប់ដើមឆ្នាំ ២០១៣ គឺមានដូចតទៅនេះ៖

| <u>ថ្ងៃទី ០៨, ០៩, ១០, ១១ ខែ មករា ឆ្នាំ ២០១៣</u> | <u>ថ្ងៃទី ០៥, ០៦, ០៧, ០៨ ខែ កុម្ភៈ</u> |
|---|---|
| • TCW-620 (ក.ស.ព/សហមេធាវីនាំមុខ មួយថ្ងៃ; | • TCW-126 (ក.ស.ព/សហមេធាវីនាំមុខ កន្លះថ្ងៃ; |

Δ មួយថ្ងៃ)

- TCW-754 (ក.ស.ព/សហមេធាវីនាំមុខ មួយថ្ងៃ; Δ មួយថ្ងៃ)

<u>ថ្ងៃទី ១៤, ១៥, ១៦ ខែ មករា</u>

- TCW-100 (ក.ស.ព/សហមេធាវីនាំមុខ មួយថ្ងៃ; Δ មួយថ្ងៃ)
- TCW-548 (ក.ស.ព/សហមេធាវីនាំមុខ កន្លះថ្ងៃ; Δ កន្លះថ្ងៃ)

<u>ថ្ងៃទី ២១, ២២, ២៣, ២៤ ខែ មករា</u>

- TCW-536 (អ.ជ.ស.ដ មួយថ្ងៃ; ក.ស.ព/សហមេធាវីនាំមុខ កន្លះថ្ងៃ; Δ មួយថ្ងៃ)
- TCW-253 (ក.ស.ព/សហមេធាវីនាំមុខ កន្លះថ្ងៃ; Δ កន្លះថ្ងៃ)
- TCW-565 (ក.ស.ព/សហមេធាវីនាំមុខ កន្លះថ្ងៃ; Δ កន្លះថ្ងៃ)

<u>ថ្ងៃទី ២៨, ២៩, ៣០, ២៤ ខែ មករា</u>

- TCCP-94 (ក.ស.ព/សហមេធាវីនាំមុខ កន្លះថ្ងៃ; Δ កន្លះថ្ងៃ)
- TCW-110 (ក.ស.ព/សហមេធាវីនាំមុខ មួយថ្ងៃ; Δ មួយថ្ងៃ)

Δ កន្លះថ្ងៃ)

- TCW-570 (ក.ស.ព/សហមេធាវីនាំមុខ កន្លះថ្ងៃ; Δ កន្លះថ្ងៃ)
- TCW-752 (ក.ស.ព/សហមេធាវីនាំមុខ កន្លះថ្ងៃ; Δ កន្លះថ្ងៃ)
- សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណី កំពុងស្ថិតនៅក្នុងការពិចារណា និងជូនដំណឹងពេលក្រោយ

<u>ថ្ងៃទី ១១, ១២, ១៣, ១៤ ខែ កុម្ភៈ</u>

- TCE-80 (បួនថ្ងៃ) (អ.ជ.ស.ដ មួយថ្ងៃ; ក.ស.ព/សហមេធាវីនាំមុខ មួយថ្ងៃកន្លះ; Δ មួយថ្ងៃកន្លះ)

<u>ថ្ងៃទី ១៨, ១៩, ២០, ២១ ខែ កុម្ភៈ</u>

- សវនាការលើឯកសារ**

<u>ថ្ងៃទី ២៥ ខែ កុម្ភៈ ដល់ ថ្ងៃទី ០១ ខែ មីនា</u>

- អង្គជំនុំជម្រះផ្អាកមិនធ្វើសវនាការ

<u>ថ្ងៃទី ០៤, ០៥, ០៦, ០៧ ខែ មីនា</u>

- TCE-65 (អ.ជ.ស.ដ មួយថ្ងៃ; ក.ស.ព/ សហមេធាវីនាំមុខ មួយថ្ងៃកន្លះ; Δ មួយថ្ងៃកន្លះ)

Δ = ក្រុមមេធាវីការពារក្តីទាំងអស់

** នីតិវិធីសម្រាប់សវនាការលើឯកសារចាប់ពីថ្ងៃទី ១៨ ដល់ថ្ងៃទី ២១ នឹងត្រូវជូនដំណឹងដល់ភាគីនានានៅក្នុងពេលវេលាសមស្របខាងមុខ។

កាលបរិច្ឆេទដូចបានបញ្ជាក់ខាងលើទាំងនេះអាចនឹងកែប្រែ ប្រសិនបើចាំបាច់ដើម្បីគ្រប់គ្រងសវនាការ ឲ្យមានប្រសិទ្ធភាព។